ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១ ប.ប

## បទបញ្ជារបស់រាជរដ្ឋាភិបាល
## ស្តីពីការចាត់វិធានការលុបបំបាត់ភាពអនាធិបតេយ្យ
## នៃការដាក់សំរះ ឆ្នស់ ព្រួល និងសំណង់កាត់ទទឹងទន្លេ ស្ទឹង ព្រែក អូរ
## និងបឹងបួរ នៅតាមបណ្តាខេត្តពាក់ព័ន្ធនឹងបឹងទន្លេសាប

នៅក្នុងពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលសង្កេតឃើញថា នៅក្នុងភូមិសាស្ត្រខេត្តទាំង ៨ ជុំវិញបឹងទន្លេសាប រួមមាន : ខេត្តកំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម និងខេត្តកណ្តាល នៅមានសកម្មភាពដាក់សំរះ ឆ្នស់ ព្រួល និងសាងសង់សំណង់កាត់ទទឹងទន្លេ ស្ទឹង ព្រែក អូរ បឹងបួរ ដែលសកម្មភាពអវិជ្ជមានទាំងនេះ បានបង្កជាឧបសគ្គដល់ការធ្វើចរាចរនៃជលយានគ្រប់ប្រភេទ របបជលសាស្ត្រ ការបំលាស់ទីរបស់មច្ឆជាតិគ្រប់ប្រភេទ ព្រមទាំងជាកត្តាបង្កឱ្យមានការគោករាក់យ៉ាងឆាប់រហ័សដល់ទន្លេ ស្ទឹង ព្រែក បឹងបួរ ទាំងនោះផងដែរ ។

ដើម្បីឈានទៅលុបបំបាត់ទាំងស្រុងនូវសកម្មភាពអនាធិបតេយ្យទាំងនេះ រាជរដ្ឋាភិបាលសូមដាក់ចេញនូវបទបញ្ជាដល់ក្រសួង-ស្ថាប័ន និងអាជ្ញាធរខេត្តពាក់ព័ន្ធនឹងរបបជលសាស្ត្រនៃបឹងទន្លេសាបទាំងអស់ ដើម្បីចុះអនុវត្តតាមការណែនាំ ដូចខាងក្រោម :

១- ជំហានទី ១ : អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម និងខេត្តកណ្តាលត្រូវអញ្ជើញម្ចាស់សំរះ ឆ្នស់ ព្រួល និងសំណង់កាត់ទទឹងទន្លេ ស្ទឹង ព្រែក អូរ បឹងបួរ គ្រប់ប្រភេទ មកធ្វើការណែនាំ និងតម្រូវឱ្យរុះរើសំណង់ទាំងនោះចេញដោយខ្លួនឯង ដោយរាជរដ្ឋាភិបាលទុករយៈពេល ២ សប្តាហ៍ជូន ។

២- ជំហានទី ២ : ផុតរយៈពេលឱសានវាទ ( ២ សប្តាហ៍ ) ខាងលើ បើម្ចាស់សំណង់ទាំងនោះមិនធ្វើការរុះរើទេនោះ ក្រសួងធនធានទឹក និងឧតុនិយមនឹងសហការជាមួយអាជ្ញាធរទន្លេសាប អាជ្ញាធរខេត្តពាក់ព័ន្ធ និងកម្លាំងអន្តរាគមន៍ពិសេសចុះបំផ្លាញចោលទាំងស្រុង និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីផ្តន្ទាទោសទៅតាមច្បាប់ ដូចមានចែងត្រង់ចំណុច ៣ មាត្រា ៣៦ ជំពូកទី ១០ នៃ ច្បាប់ស្តីពី " ការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា " ។ ម្ចាស់សំណង់ត្រូវចេញសោហ៊ុយសម្រាប់ការងារប្រតិបត្តិការខាងលើនេះ ។

៣- រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធានអាជ្ញាធរទន្លេសាប អភិបាលនៃគណៈអភិបាលខេត្តទាំង ៨ ខាងលើ ប្រធានក្រុមអន្តរាគមន៍ពិសេសត្រូវអនុវត្តឱ្យបានសម្រេចនូវបទបញ្ជារបស់រាជរដ្ឋាភិបាលដូចមានចែងក្នុងចំណុច ១ និងចំណុច ២ នៃបទបញ្ជានេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០១១*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**